# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ៦៨៧,២៦៦ ដុល្លារអាមេរិកដើម្បីបង្កើនប្រសិទ្ធភាពបោសសម្អាត សំណល់ជាតផ្ទុះពីសង្គ្រាមក្នុងខេត្តភាគខាងជើង និងភាគកណ្តាល (ឆ្នាំ២០១៣)



ក្រោមគ្រោងការណ៍ នៃ ជំនួយ ឧបត្ថម្ភ ឥតសំណង សម្រាប់គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៥៦,៣៥៥,៨១២ យ៉េន (ប្រមាណ៦៨៧,២៦៦ ដុល្លារអាមេរិក) ដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកតាកាគូវ៉ា ហ្វ៊ូមីតូហ្ស៊ី ប្រធានតំណាងអង្គការ JMAS ដើម្បីអនុវត្តគម្រោង។



តាមរយៈគម្រោងនេះ JMAS នឹង ផ្តល់ជាជំនួយបច្ចេកទេស ដល់ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC)ដើម្បីបង្កើនសកម្មភាពបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាមក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត JMASនឹងប្រើប្រាស់ក្រុមបោសសម្អាតអាវុធជាតិផ្ទុះ៦ក្រុមដោយសហការជាមួយCMACក្នុងខេត្តសៀមរាប កំពង់ធំ ពោធិ៍សាត់ និងកំពង់ឆ្នាំង ទីដែលប្រជាជននៅតែរងគ្រោះដោយសំណល់ជាតិផ្ទុះពីសង្គ្រាម។ JMAS ក៏នឹងប្រើប្រាស់ក្រុមកាត់បន្ថយគ្រោះថ្នាក់ដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះតាមសហគមន៍ក្នុងការប្រមូលពត៌មានទាក់ទងនឹងសំណល់ជាតិផ្ទុះពីសង្គ្រាម ព្រមទាំងអនុវត្តសកម្មភាពបង្កើនការយល់ដឹងសម្រាប់ប្រជាជនក្នុងតំបន់ ដើម្បីជួយឲ្យពួកគេយល់ដឹងអំពីគ្រោះថ្នាក់នៃសំណល់ជាតិផ្ទុះពី សង្គ្រាម និងជៀសវាងគ្រោះថ្នាក់ដែលបណ្តាលមកពីការធ្វេសប្រហែសចំពោះសំណល់ជាតិផ្ទុះពីសង្គ្រាម។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង១៩.៣លាន ដុល្លាអាមេរិកដល់គម្រោងចំនួន ៧៣គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី៣តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣របស់ជប៉ុន(មេសា២០១៣ដល់មិនា២០១៤)។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ័៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*